- បានឃើញប្រកាសលេខ១៧២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីហិរញ្ញវត្ថុ ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់ គ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ ._**

ត្រូវបានតែងតាំងមន្ត្រីរាជការ របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | លោក | **អូ ចិន្តា** | ជាគណនេយ្យករ បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២. | លោក | **ចេង សារា** | ជាជំនួយការគណនេយ្យករ |

**ប្រការ២ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .—**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋានពាក់ព័ន្ធ អគ្គាធិការនៃអគ្គាធិការដ្ឋាន និង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ... ខែ ... ឆ្នាំ ... ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០២២

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល**

-ទីស្តីការ គណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-ក្រសួងអប់រំ យុវជន និងកីឡា
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.........សហវ.....

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ សម្រាប់ប្រើប្រាស់ផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដំណាក់កាលទី១

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២០/០៣១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១៦៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និង អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាននិងនីតិវិធី នៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បានឃើញបទបញ្ជាលេខ ៣០ បប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- បានឃើញសារាចរលេខ ០៧ សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បានឃើញប្រកាសលេខ ០០២ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ស្តីពីវិធាន និងនីតិវិធីលម្អិតនៃការជម្រះ បញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បានឃើញប្រកាសលេខ ០០៧ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ ស្តីពីការកំណត់អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (State Asset Management-SAM) សម្រាប់ប្រើប្រាស់ផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដំណាក់កាលទី១ លើមុខងារចំនួន ០៣ ចាប់ពីខែកុម្ភៈ ឆ្នាំ២០២២តទៅ ដល់គ្រប់អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានដូចខាងក្រោម÷

**១.មុខងារបញ្ជីសារពើភណ្ឌ÷** អង្គភាពប្រើប្រាស់ ត្រូវពិនិត្យ ផ្ទៀងផ្ទាត់ និងផ្ទុកទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់សាមីអង្គភាពនីមួយៗនៅក្នុងប្រព័ន្ធ SAM ដែលបានបញ្ចូលដោយក្រុមការងារ នៃលេខាធិការដ្ឋាន គ.ប.ទ.។

**២.មុខងារមតិយោបល់÷** អង្គភាពប្រើប្រាស់ ត្រូវពិនិត្យ និងផ្តល់មតិយោបល់តាមរយៈមុខងារមតិយោបល់របស់ប្រព័ន្ធ SAM ដើម្បីផ្តល់ព័ត៌មានត្រឡប់មកវិញ និង/ឬ ដោះស្រាយចម្ងល់ ឬបញ្ហាផ្សេងៗ បានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

**៣.មុខងាររបាយការណ៍÷**អង្គភាពប្រើប្រាស់ ត្រូវទាញយករបាយការណ៍ដែលផលិតចេញពីប្រព័ន្ធ ដោយស្វ័យប្រវត្តិ ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន ដោយបោះពុម្ព និងចងក្រងបញ្ជីសារពើភណ្ឌឱ្យបានចប់សព្វគ្រប់យ៉ាងយូរត្រឹមដំណាច់ត្រីមាសទី១ នៃឆ្នាំបន្ទាប់ រួចបញ្ជូនមកលេខាធិការដ្ឋានគ.ប.ទ. ចំនួន០៥ច្បាប់ ដើម្បីតម្កល់ទុកជាផ្លូវការ និងចាត់ចែងបន្តតាមនីតិវិធីជាធរមាន។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងប្រធានអង្គភាពប្រើប្រាស់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពប្រើប្រាស់ថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន នៃគសហវ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.ប្រក

# ប្រកាស
# ស្តីពី
# គ្នាក់ងារសេវាកម្មពន្ធដារ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

### ប្រការ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់លក្ខណវិនិច្ឆ័យ និងគ្រប់គ្រងបុគ្គលដែលធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ ដើម្បីធានាការផ្តល់សេវាឱ្យអ្នកជាប់ពន្ធរបស់ភ្នាក់ងារសេវាកម្មពន្ធដារ ប្រកបដោយគុណភាព និងវិជ្ជាជីវៈ ដើម្បីឱ្យអ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារ អនុវត្តត្រឹមត្រូវ ទាន់ពេលវេលា និងទប់ស្កាត់បាននូវអំពើគេចវេះពន្ធ។

### ប្រការ២.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលដែលធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលធ្វើការផ្តត់ផ្គង់សេវាទាក់ទិននឹងពន្ធដារដល់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

ភ្នាក់ងារសេវាកម្មពន្ធដារ អាចធ្វើការផ្គត់ផ្គង់សេវាទាក់ទិននឹងពន្ធដារដល់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសផង និងអ្នកជាប់ពន្ធមិនស្ថិតក្នុងរបបស្វ័យប្រកាសផង។ អ្នកជាប់ពន្ធដែលមិននៅក្នុងរបបស្វ័យប្រកាស អាចទទួលបានការផ្គត់ផ្គង់សេវាទាក់ទិននឹងពន្ធដារ ដោយបុគ្គលដទៃទៀតក្រៅពីភ្នាក់ងារសេវាកម្មពន្ធដារ។

### ប្រការ៣.- និយមន័យ

សម្រាប់គោលដៅនៃប្រកាសនេះ÷

១- ពាក្យ "បុគ្គល" សំដៅដល់ រូបវន្តបុគ្គល នីតិបុគ្គល និងសហគ្រាសសហកម្មសិទ្ធិ ដូចមានចែងក្នុងមាត្រា៣ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

២- ពាក្យ "វិញ្ញាបនបត្រជំនាញវិជ្ជាជីវៈពន្ធដារ" សំដៅដល់ វិញ្ញាបនបត្រចេញដោយអគ្គនាយកដ្ឋានពន្ធដារ ដែលបេក្ខជនបានប្រឡងជាប់ជាស្ថាពរជំនាញវិជ្ជាជីវៈពន្ធដារ។

៣- ពាក្យ "ភ្នាក់ងារសេវាកម្មពន្ធដារ" សំដៅដល់ បុគ្គលដែលទទួលបានអាជ្ញាប័ណ្ណជាភ្នាក់ងារសេវាកម្មពន្ធដារ ពីអគ្គនាយកដ្ឋានពន្ធដារ។

៤- ពាក្យ "ស្ថាប័នមានសមត្ថកិច្ច" សំដៅដល់ ស្ថាប័នឬអាជ្ញាធរមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

៥- ពាក្យ "អាជ្ញាប័ណ្ណ" សំដៅដល់ អាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ។

### ប្រការ៤.- លក្ខណវិនិច្ឆ័យ និងលក្ខខណ្ឌក្នុងការស្នើសុំអាជ្ញាប័ណ្ណ

១- បុគ្គលដែលមានបំណងធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវមានអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ។

២- ពាក្យស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវស្នើសុំទៅអគ្គនាយដ្ឋានពន្ធដារ តាមទម្រង់ និងសេចក្តីណែនាំ ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។

៣- ភ្នាក់ងារសេវាកម្មពន្ធដារត្រូវចុះបញ្ជីពន្ធដារ ជាអ្នកជាប់ពន្ធមធ្យមឬធំ និងបំពេញលក្ខខណ្ឌណាមួយដូចខាងក្រោម÷

ក- បុគ្គលមានវិញ្ញាបនបត្រជំនាញវិជ្ជាជីវៈពន្ធដារចេញដោយអគ្គនាយកដ្ឋានពន្ធដារ ដែលមានសុពលភាព ឬ

ខ- ក្រុមហ៊ុននីតិបុគ្គល ឬក្រុមហ៊ុនសហកម្មសិទ្ធិ ដែលទទួលបានអាជ្ញាប័ណ្ណសេវាកម្មគណនេយ្យនិងសវនកម្មដែលចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ

គ- គណនេយ្យករ និងសវនករជំនាញ ដែលជាសមាជិកវិទ្យាស្ថានគណនេយ្យករ និងសវនករជំនាញកម្ពុជា ឬ

ឃ- អតីតមន្ត្រីពន្ធដារ ហើយធ្លាប់បានបម្រើការងារនៅរដ្ឋបាលសារពើពន្ធកម្ពុជាចាប់ពី ១០ឆ្នាំឡើងទៅ និងមិនធ្លាប់ប្រព្រឹត្តបទល្មើសទាក់ទិននឹងពន្ធដារ ឬផ្សំគំនិតជាមួយអ្នកជាប់ពន្ធក្នុងការគេចវេះពន្ធ ឬបន្ថិប្រាក់ពន្ធ និងមិនធ្លាប់ទទួលពិន័យផ្សេងៗពីអគ្គនាយកដ្ឋានពន្ធដារ ឬពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬពីតុលាការ។

### ប្រការ៥.- បែបបទនិងនីតិវិធីនៃការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ

បែបបទនិងនីតិវិធីនៃការដាក់ពាក្យស្នើសុំ បន្ត ព្យួរនិងបច្ចុប្បន្នភាពអាជ្ញាប័ណ្ណ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ។

### ប្រការ៦.- អ្នកតំណាង

បុគ្គលដែលមានបំណងស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវមានអ្នកតំណាងម្នាក់ដែលជានាយក ឬបណ្ណាធិការ ឬកម្មសិទ្ធិករម្នាក់ដែលកាន់កាប់ភាគហ៊ុន ឬសិទ្ធិបោះឆ្នោតលើសពី ៥០% ហើយបានបំពេញលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌដែលមានចែងក្នុងប្រការ៤ នៃប្រកាសនេះ។

### ប្រការ៧.- ការផ្លាស់ប្តូរអ្នកតំណាង

ក្នុងករណីភ្នាក់ងារសេវាកម្មពន្ធដារជាក្រុមហ៊ុននីតិបុគ្គល ឬសហគ្រាសសហកម្មសិទ្ធិ មានការផ្លាស់ប្តូរអ្នកតំណាងម្នាក់ដែលជានាយក ឬបណ្ណាធិការ ឬកម្មសិទ្ធិករម្នាក់ដែលកាន់កាប់ភាគហ៊ុន ឬសិទ្ធិបោះឆ្នោតលើសពី ៥០% ត្រូវមកធ្វើបច្ចុប្បន្នភាពនៅអគ្គនាយកដ្ឋានពន្ធដារយ៉ាងយឺតបំផុត ១៥ថ្ងៃ មុនការផ្លាស់ប្តូរ។

### ប្រការ៨.- សិទ្ធិរបស់ភ្នាក់ងារសេវាកម្មពន្ធដារ

បន្ថែមលើសិទ្ធិដែលមានចែងក្នុងមាត្រា១០៦ នៃច្បាប់ស្តីពីសារពើពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារ ដែលមានលិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរធ្វើជាអ្នកតំណាងស្របច្បាប់ពីអ្នកជាប់ពន្ធ មានសិទ្ធិជំនួសមុខឱ្យអ្នកជាប់ពន្ធក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធដូចខាងក្រោម÷

១- ធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ

២- បំពេញបែបបទពន្ធដារ

៣- ដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ប្រចាំឆ្នាំ និងបង់ពន្ធអាករទាំងឡាយ ដែលកំណត់ដោយច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ

៤- ចុះហត្ថលេខាជំនួសអ្នកជាប់ពន្ធ

៥- បង្ហាញនិងផ្តល់ឯកសារ របាយការណ៍ ឬលិខិតយុត្តិការផ្សេងៗពាក់ព័ន្ធនឹងពន្ធដាររបស់អ្នកជាប់ពន្ធដល់រដ្ឋបាលសារពើពន្ធ

៦- ធ្វើបណ្តឹងតវ៉ា និងបណ្តឹងឧទ្ធរណ៍ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធដារ

៧- បំពេញរាល់កាតព្វកិច្ចដែលអ្នកជាប់ពន្ធ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ

៨- ទទួលព័ត៌មានជាប្រចាំអំពីការធ្វើបច្ចុប្បន្នភាព ឬវិសោធនកម្មនៃច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ

៩- ធ្វើជាដៃគូសហប្រតិបត្តិការល្អជាមួយរដ្ឋបាលសារពើពន្ធ ក្នុងគោលបំណងដើម្បី÷

ក. ពង្រីកនិងពង្រឹងការផ្តល់សេវា និងការអប់រំដល់អ្នកជាប់ពន្ធឱ្យទាន់ពេលវេលា និងអាចទុកចិត្តបាន ដើម្បីធានាឱ្យការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារបានល្អប្រសើរ

ខ. ទប់ស្កាត់សកម្មភាពគេចវេះពន្ធ

គ. ផ្តល់អនុសាសន៍សម្រាប់ជាធាតុចូលដើម្បីបំពេញបន្ថែម និងអភិវឌ្ឍន៍ច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងទំនើបកម្ម។

**ប្រការ៩.- កាតព្វកិច្ចរបស់ភ្នាក់ងារសេវាកម្មពន្ធដារ**

ភ្នាក់ងារសេវាកម្មពន្ធដារ មានកាតព្វកិច្ចដូចខាងក្រោម÷

១- ធ្វើសកម្មភាពអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដារនៅទីតាំង ដែលទទួលបានការអនុញ្ញាតពីអគ្គនាយកដ្ឋានពន្ធដារ ដោយមានដាក់ស្លាកយីហោជាភ្នាក់ងារសេវាកម្មពន្ធដារ

២- ប្រកាស និងបង់ពន្ធឱ្យបានត្រឹមត្រូវ ទាន់ពេលវេលាតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ

៣- ផ្តល់សេវាផ្សេងៗដល់អ្នកជាប់ពន្ធទាក់ទិននឹងពន្ធដារ ប្រកបដោយវិជ្ជាជីវៈ និងសុចរិតភាព

៤- សម្របសម្រួលដើម្បីឱ្យអ្នកជាប់ពន្ធអនុវត្តកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ

៥- ជួយអ្នកជាប់ពន្ធឱ្យអនុវត្តកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ

៦- រួមចំណែកទប់ស្កាត់បទល្មើសកេងបន្លំប្រាក់ពន្ធ តាមរយៈការផ្តល់ព័ត៌មានជូនរដ្ឋបាលសារពើពន្ធអំពីសកម្មភាពគេចវេះពន្ធ

៧- ផ្តល់លិខិតផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីអតិថិជនរបស់ខ្លួន និងបង្ហាញអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារជូនមន្ត្រីពន្ធដារក្នុងពេលបំពេញភារកិច្ចជាតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ

៨- ទំនាក់ទំនង ឬធ្វើការជាមួយរដ្ឋបាលសារពើពន្ធប្រកបដោយភាពស្មោះត្រង់

៩- ផ្តល់ឯកសារ កំណត់ត្រា បញ្ជីគណនេយ្យ និងព័ត៌មានផ្សេងៗទៀតទាក់ទិននឹងសកម្មភាពអាជីវកម្មរបស់អតិថិជន តាមសំណើរបស់រដ្ឋបាលសារពើពន្ធ

១០-មិនត្រូវបង្ហាញ និងផ្តល់ព័ត៌មានសម្ងាត់នានាទាក់ទិននឹងពន្ធដារ របស់អតិថិជនខ្លួនទៅតតិយជនដោយគ្មានការអនុញ្ញាតពីអតិថិជនខ្លួនឡើយ លើកលែងតែមន្ត្រីពន្ធដារក្នុងពេល និងក្នុងគោលដៅបំពេញភារកិច្ចជាផ្លូវការតាមបទប្បញ្ញត្តិស្តីពីពន្ធដារ

១១-ផ្តល់ជូនអគ្គនាយកដ្ឋានពន្ធដារនូវបញ្ជីឈ្មោះបុគ្គលិក ដែលផ្តល់សេវាកម្មពន្ធដារជារៀងរាល់ចុងខែ

១២-បន្តបង្កើន និងធ្វើបច្ចុប្បន្នភាពចំណេះដឹងទាក់ទិននឹងវិជ្ជាជីវៈរបស់ខ្លួន ដើម្បីធានាថាសេវាកម្ម ដែលត្រូវបានផ្តល់ឱ្យអតិថិជន ប្រកបដោយវិជ្ជាជីវៈ ត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ប្រការ១០.- ការអនុវត្តកាតព្វកិច្ចសារពើពន្ធ**

១- អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក(នាយក បណ្ណាធិការ កម្មសិទ្ធិករ គណនេយ្យករ និងបុគ្គលិកទទួលសិទ្ធិរបស់សហគ្រាស) អាចបំពេញបែបបទពន្ធដារ ដាក់លិខិតប្រកាសពន្ធ បង់ប្រាក់ពន្ធប្រចាំខែ ប្រចាំឆ្នាំ និងធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធសម្រាប់សហគ្រាសខ្លួនផ្ទាល់ និងមិនត្រូវបានចាត់ទុកថាជាភ្នាក់ងារ



ហ្គ

សេវាកម្មពន្ធដារឡើយ។ និយោជក ឬនិយោជិតរបស់សហគ្រាស ត្រូវពាក់ប័ណ្ណសម្គាល់ក្នុងពេលធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ។

២- បុគ្គលទាំងឡាយណា ដែលទទួលបានអាជ្ញាប័ណ្ណជាភ្នាក់ងារសេវាកម្មពន្ធដារ ពីអគ្គនាយកដ្ឋានពន្ធដារមានសិទ្ធិធ្វើជាអ្នកតំណាង ឬចាត់បុគ្គលិកជំនួសមុខឱ្យអ្នកជាប់ពន្ធ ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ បន្ទាប់ពីទទួលបានសិទ្ធិស្របច្បាប់ជាអ្នកតំណាងពីអ្នកជាប់ពន្ធ។

៣- ភ្នាក់ងារសេវាកម្មពន្ធដារ អាចបំពេញសេវាកម្មជូនអ្នកជាប់ពន្ធ តាមរយៈបុគ្គលិករបស់ខ្លួនដោយមានលិខិតបញ្ជាក់ប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ និងត្រូវពាក់ប័ណ្ណសម្គាល់បុគ្គលិកភ្នាក់ងារសេវាកម្មពន្ធដារ ក្នុងពេលបំពេញភារកិច្ចជាមួយរដ្ឋបាលសារពើពន្ធ។

៤- អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក អាចដាក់ពាក្យបណ្ដឹងតវ៉ាមកអគ្គនាយកដ្ឋានពន្ធដារ ក្នុងករណីភ្នាក់ងារសេវាកម្មពន្ធដារ មិនគោរពកាតព្វកិច្ច ឬមិនបានផ្ដល់សេវាទាក់ទិននឹងពន្ធដារប្រកបដោយវិជ្ជាជីវៈនិងសុចរិតភាព។

**ប្រការ១១.- រយៈកាលនៃអាជ្ញាប័ណ្ណ និងការស្នើសុំអាជ្ញាប័ណ្ណបន្ត**

១- អាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវចេញដោយអគ្គនាយកដ្ឋានពន្ធដារ ហើយអាជ្ញាប័ណ្ណនេះមានសុពលភាពរយៈពេល ២ (ពីរ)ឆ្នាំ។

២- ភ្នាក់ងារសេវាកម្មពន្ធដារ ត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណក្នុងរយៈពេលយ៉ាងយឺតបំផុត ៣០ថ្ងៃ មុនរយៈពេលដែលអាជ្ញាប័ណ្ណចាស់ផុតសុពលភាព។ ការស្នើសុំបន្តអាជ្ញាប័ណ្ណ ត្រូវដាក់ជូនអគ្គនាយកដ្ឋានពន្ធដារតាមបែបបទ និងនីតិវិធីដូចមានចែងក្នុងប្រការ៥ នៃប្រកាសនេះ។

៣- ភ្នាក់ងារសេវាកម្មពន្ធដារ គ្មានសិទ្ធិបន្តប្រកបអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារឡើយ ប្រសិនបើអាជ្ញាប័ណ្ណដែលបុគ្គលនោះកាន់កាប់ផុតសុពលភាព។

**ប្រការ១២.- ការបដិសេធ និងការតវ៉ាពាក្យស្នើសុំអាជ្ញាប័ណ្ណ**

ពាក្យស្នើសុំអាជ្ញាប័ណ្ណអាចត្រូវបានបដិសេធ ប្រសិនបើបុគ្គលស្នើសុំមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមលក្ខណវិនិច្ឆ័យដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ។ ក្រោយពេលទទួលបាននូវសេចក្ដីជូនដំណឹងពីការបដិសេធ បុគ្គលស្នើសុំអាចតវ៉ាទៅអគ្គនាយកដ្ឋានពន្ធដារ ដើម្បីសុំពិនិត្យឡើងវិញនូវសេចក្ដីសម្រេចបដិសេធនោះ ដោយបញ្ជាក់នូវមូលហេតុ និងភស្តុតាងបន្ថែមនានា។

**ប្រការ១៣.- កម្រៃអាជ្ញាប័ណ្ណ**

១- នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ឬបន្តអាជ្ញាប័ណ្ណ ត្រូវបង់កម្រៃអាជ្ញាប័ណ្ណ ជូនអគ្គនាយកដ្ឋានពន្ធដារចំនួន ២ ០០០ ០០០ រៀល (ពីរលានរៀល)។

២- កម្រៃអាជ្ញាប័ណ្ណដែលបានបង់ហើយ មិនត្រូវបានបង្វិលសងវិញឡើយ។

**ប្រការ១៤.- ការព្យួរទុក និងការលុបចោលអាជ្ញាប័ណ្ណ**

អគ្គនាយកដ្ឋានពន្ធដារ អាចព្យួរទុក ឬលុបចោលនូវអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ក្នុងករណីដែលភ្នាក់ងារសេវាកម្មពន្ធដារ៖

១- ខកខានមិនអនុវត្តបានត្រឹមត្រូវតាមប្រកាសនេះ

២- ល្មើសច្បាប់និងបទប្បញ្ញត្តិស្ដីពីពន្ធដារ

៣- ធ្វើ ឬផ្តល់យោបល់ ឬចូលរួមជាមួយអតិថិជន ក្នុងសកម្មភាពលួចបន្លំប្រាក់ពន្ធ

៤- ផ្តល់យោបល់ ឬផ្តល់សេវាផ្សេងៗដល់អតិថិជនមិនត្រឹមត្រូវ ដែលនាំឱ្យអតិថិជនប្រព្រឹត្តខុសច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ

៥- មានចេតនាធ្វើឱ្យរាំងស្ទះដល់ការកំណត់ពន្ធ និងការប្រមូលពន្ធ

៦- កេងបន្លំប្រាក់ពន្ធរបស់ស្ថាប័នរដ្ឋ និងអតិថិជន

៧- ជាប់បំណុលមិនអាចសងរួច ឬក្ស័យធន

៨- បាត់បង់សមត្ថភាព ដោយមូលហេតុផ្សេងៗ ដែលមិនអាចបំពេញឱ្យបានត្រឹមត្រូវនូវកាតព្វកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនជាភ្នាក់ងារសេវាកម្មពន្ធដារ

៩- ប្រព្រឹត្តល្មើសច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន ដែលមានកម្រិតធ្ងន់ធ្ងរ

១០-ឈប់ធ្វើអាជីវកម្មជាភ្នាក់ងារសេវាកម្មពន្ធដារ

១១-មិនបានគោរពនូវគោលការណ៍នៃការបណ្តុះបណ្តាល និងបច្ចុប្បន្នភាពចំណេះដឹង របស់អគ្គនាយកដ្ឋានពន្ធដារ ការព្យួរ ឬការលុបចោលអាជ្ញាប័ណ្ណជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ មិនត្រូវបានផ្តល់នូវសំណង ឬជំងឺចិត្តឡើយ។

**ប្រការ១៥.- បទល្មើស និងទោសទណ្ឌ**

១- ភ្នាក់ងារសេវាកម្មពន្ធដារ ប្រើប្រាស់អាជ្ញាប័ណ្ណផុតសុពលភាព ត្រូវទទួលរងពិន័យស្មើ ១០០% (មួយរយភាគរយ)នៃកម្រៃអាជ្ញាប័ណ្ណ បូកនឹងការប្រាក់ ១.៥% នៃកម្រៃអាជ្ញាប័ណ្ណ ក្នុងមួយខែ គិតចាប់ពីខែបន្ទាប់នៃខែដែលកម្រៃអាជ្ញាប័ណ្ណត្រូវបង់ និង/ឬផ្អាកជាបណ្តោះអាសន្នសកម្មភាពអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដាររយៈពេល ៣ខែ។

២- ភ្នាក់ងារសេវាកម្មពន្ធដារ ដែលប្រព្រឹត្តល្មើសដូចមានចែងក្នុងកថាខណ្ឌ១ ដល់កថាខណ្ឌ៦ នៃប្រការ ១៤ នៃប្រកាសនេះ ត្រូវរងពិន័យជាប្រាក់ ៥ ០០០ ០០០រៀល (ប្រាំលានរៀល) ឬផ្អាកសកម្មភាពអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដាររយៈពេលពី ៣ខែ ដល់១ឆ្នាំ ឬដកហូតអាជ្ញាប័ណ្ណបញ្ឈប់សកម្មភាពអាជីកម្មភ្នាក់ងារសេវាកម្មពន្ធដារជាស្ថាពរ។

៣- បុគ្គលដែលពុំមែនជាភ្នាក់ងារសេវាកម្មពន្ធដារ ធ្វើអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដារ ដោយគ្មានអាជ្ញាប័ណ្ណ ត្រូវចាត់ទុកថាប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា១២៨ និងត្រូវទទួលរងការផ្តន្ទាទោស តាមមាត្រា១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ ដោយពិន័យជាប្រាក់ពី ៥ ០០០ ០០០ រៀល (ប្រាំលានរៀល) ដល់ ១០ ០០០ ០០០រៀល (ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ខែ ដល់១ឆ្នាំ ឬទោសទាំងពីរនេះ ចំពោះរូបវន្តបុគ្គល ឬអ្នកទទួលខុសត្រូវរបស់ក្រុមហ៊ុននីតិបុគ្គល និងសហគ្រាសសហកម្មសិទ្ធិ រួមមាន នាយក ឬបណ្ណាធិការ ឬកម្មសិទ្ធិករដែលកាន់កាប់ក្រុមហ៊ុន ឬសិទ្ធិបោះឆ្នោតលើសពី ៥០%។

៤- អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលទទួលការផ្គត់ផ្គង់សេវាកម្មពន្ធដារ ពីបុគ្គលដែលមិនមែនជាភ្នាក់ងារសេវាកម្មពន្ធដារ ដែលធ្វើអាជីវកម្មភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាប័ណ្ណ ត្រូវរងពិន័យជាប្រាក់ចំនួន ៥ ០០០ ០០០រៀល (ប្រាំលានរៀល)។

៥- អ្នកជាប់ពន្ធដែលមិនស្ថិតក្នុងរបបស្វ័យប្រកាស អាចទទួលបានការផ្គត់ផ្គង់សេវាទាក់ទិននឹងពន្ធដារ ដោយបុគ្គល ដែលគ្មានអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ ដោយពុំទទួលរងពិន័យដូចមានចែងក្នុងកថាខណ្ឌ៤ នៃប្រការនេះ ចំពោះប្រភេទពន្ធមួយចំនួន ដែលមិនស្ថិតនៅក្នុងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធតាមរបប



K-1

ស្វ័យប្រកាស ដូចជា ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ពន្ធលើឈ្នួលផ្ទះនិងដី និងពន្ធប្រថាប់ត្រា។

**ប្រការ១៦.- និរាករណ៍**

ប្រកាសលេខ ៤៥៥ សហវ.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៣ ស្តីពីភ្នាក់ងារសេវាកម្មពន្ធដារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៧.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ [illegible] ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២២

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ១៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ប្រក

# ប្រកាស
## ស្ដីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ដើម្បីធានាគុណភាព ចីរភាព និងប្រសិទ្ធភាពនៃលទ្ធផលបេសកកម្មការងារក្នុងវិស័យសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលសាធារណៈ។

## ជំពូកទី២
## អំពីបេសកកម្ម និងរចនាសម្ព័ន្ធ

**ប្រការ២.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលសាធារណៈ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាព។

**ប្រការ៣.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល មានភារកិច្ច ដូចតទៅ÷

- រៀបចំ និងចរចាលើរាល់កិច្ចព្រមព្រៀងរបស់រដ្ឋ ពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានឥតសំណង ការទទួលហិរញ្ញប្បទានឥតសំណង ការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី ព្រមទាំងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងៗទៀត
- គ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងសម្របសម្រួលការអនុវត្តគម្រោង/កម្មវិធីហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍, ពីការឱ្យខ្ចីផ្ទាល់, និងពីមូលបត្ររដ្ឋ
- គ្រប់គ្រងបំណុលសាធារណៈ ដោយរួមទាំងមូលបត្ររដ្ឋ
- ចូលរួមអភិវឌ្ឍមូលបត្ររដ្ឋ
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ រួមទាំងមូលនិធិទ្រទ្រង់ថវិកា និងថវិកាបដិភាគ
- ចូលរួមកសាងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា
- សហប្រតិបត្តិការសេដ្ឋកិច្ច និងហិរញ្ញវត្ថុអន្តរជាតិជាមួយអង្គភាពពាក់ព័ន្ធ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងដៃគូពាក់ព័ន្ធនានា
- បំពេញការងារផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៤.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម÷

១. នាយកដ្ឋានកិច្ចការទូទៅ

២. នាយកដ្ឋានសហប្រតិបត្តិការទ្វេភាគី

៣. នាយកដ្ឋានសហប្រតិបត្តិការពហុភាគី

៤. នាយកដ្ឋានគ្រប់គ្រងបំណុល

៥. នាយកដ្ឋានតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង

**ប្រការ៥.-**

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

អង្គការលេខរបស់អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ នៃប្រកាសនេះ។

## ជំពូកទី៣
## នាយកដ្ឋានកិច្ចការទូទៅ

**ប្រការ៦.-**

នាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង គ្រប់គ្រងបំណុល លើការងារគ្រប់គ្រងកិច្ចការទូទៅ ដោយមានតួនាទីនិងភារកិច្ច ដូចតទៅ÷

- ជាលេខាធិការដ្ឋានរបស់អគ្គនាយកដ្ឋាន
- ជាច្រកចេញ-ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់អគ្គនាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារនិងលិខិតស្នាមផ្សេងៗរបស់អគ្គនាយកដ្ឋាន
- ទទួលបន្ទុកការងារពិធីការ និងទំនាក់ទំនងសាធារណៈរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងនិងបែងចែកសម្ភារប្រើប្រាស់ ឧបករណ៍ និងមធ្យោបាយផ្សេងៗរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការងារលើកគម្រោងផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំ ក្រោមថវិកាគ្រប់គ្រង ដោយអគ្គនាយកដ្ឋាន និងទទួលបន្ទុកការងារគណនេយ្យរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការចូលរួមកសាងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា
- សម្របសម្រួល និងចូលរួមក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគសាធារណៈ
- គ្រប់គ្រងមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យារបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលនិងរៀបចំកម្មវិធីបណ្តុះបណ្តាលផ្សេងៗរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលនិងរៀបចំកម្មវិធីប្រជុំទៀងទាត់ និងរៀបចំរបាយការណ៍នៃកិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន
- រៀបចំ គ្រប់គ្រង និងថែរក្សាប្រព័ន្ធព័ត៌មានវិទ្យា រួមទាំងគេហទំព័ររបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការអនុវត្តការងារពាក់ព័ន្ធនឹងព័ត៌មានវិទ្យាគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ (FMIS)
- ចូលរួមអនុវត្តការងារពាក់ព័ន្ធនឹងធុរកិច្ចឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សម្របសម្រួល និងប្រមូលចងក្រងសរុបលទ្ធផលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងឥណទានថវិកា រួមមាន÷ បដិភាគវិនិយោគ, មូលនិធិទ្រទ្រង់ថវិកា, ចំណាយចរន្តក្នុងការអនុវត្ត គម្រោង, វិភាគទានដល់អង្គការអន្តរជាតិ, ឧបត្ថម្ភធនដល់សហគ្រាសសាធារណៈ, និងការវិនិយោគ
- រៀបចំប្រមូលចងក្រងសរុបរបាយការណ៍អនុវត្តចំណូល ចំណាយថវិកា និងរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកា
- បំពេញការងារផ្សេងទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន និងក្រសួង។

**ប្រការ៧.-**

នាយកដ្ឋានកិច្ចការទូទៅ មានការិយាល័យក្រោមឱវាទចំនួន ៣ ដូចខាងក្រោម÷

១. ការិយាល័យសរុប

២. ការិយាល័យព័ត៌មានវិទ្យា

៣. ការិយាល័យរដ្ឋបាល និងបុគ្គលិក

**ប្រការ៨.-**

ការិយាល័យសរុប មានភារកិច្ច ដូចតទៅ÷

- សម្របសម្រួលការងារលើកគម្រោងផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំ ក្រោមថវិកាទទួល បន្ទុករបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការងារចូលរួមកសាងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា
- សម្របសម្រួល និងចូលរួមក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគសាធារណៈ

- គ្រប់គ្រងឥណទានថវិកា រួមមាន៖ បដិភាគវិនិយោគ, មូលនិធិទ្រទ្រង់ថវិកា, ចំណាយចរន្តក្នុងការអនុវត្តគម្រោង, វិភាគទានដល់អង្គការអន្តរជាតិ, ឧបត្ថម្ភធនដល់សហគ្រាសសាធារណៈ, និងការវិនិយោគ
- រៀបចំបូកសរុបរបាយការណ៍អនុវត្តចំណូល ចំណាយថវិកា របាយការណ៍សមិទ្ធកម្ម
- បំពេញការងារពាក់ព័ន្ធផ្សេងទៀតតាមការចាត់តាំង។

**ប្រការ៩.-**

ការិយាល័យព័ត៌មានវិទ្យា មានភារកិច្ច ដូចតទៅ៖

- ផ្តល់ការគាំទ្រខាងបច្ចេកទេសព័ត៌មានវិទ្យាដល់នាយកដ្ឋាននានាចំណុះអគ្គនាយកដ្ឋាន
- រៀបចំ និងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងការរៀបចំ ការដំឡើង និងការថែរក្សាប្រព័ន្ធបណ្តាញ និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែត នៅក្នុងអគ្គនាយកដ្ឋាន
- រៀបចំ និងបញ្ចូលទិន្នន័យផ្សេងៗ ពាក់ព័ន្ធនឹងចំណាយថវិកាចូលទៅប្រព័ន្ធបណ្តាញ
- សម្របសម្រួលការអនុវត្តការងារពាក់ព័ន្ធនឹងព័ត៌មានវិទ្យាគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ (FMIS)
- សម្របសម្រួលការអនុវត្តការងារពាក់ព័ន្ធនឹងធុរកិច្ចឌីជីថលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញការងារពាក់ព័ន្ធផ្សេងទៀតតាមការចាត់តាំង។

**ប្រការ១០.-**

ការិយាល័យរដ្ឋបាល និងបុគ្គលិក មានភារកិច្ច ដូចតទៅ៖

- ជាច្រកចេញ-ចូលសម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់អគ្គនាយកដ្ឋាន
- រៀបចំលិខិតស្នាមរដ្ឋបាលនិងបោះពុម្ពឯកសារផ្សេងៗ
- រៀបចំគម្រោងស្នើសុំថវិការបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងនិងថែរក្សាសម្ភារប្រើប្រាស់ ឧបករណ៍ និងមធ្យោបាយផ្សេងៗរបស់អគ្គនាយកដ្ឋាន
- ទទួលបន្ទុកការងារគណនេយ្យរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យារបស់អគ្គនាយកដ្ឋាន រាប់បញ្ចូលទាំងការគ្រប់គ្រងស្ថិតិ ការលើកយោបល់លើការដំឡើងថ្នាក់និងឋានន្តរស័ក្តិ ការរៀបចំប្រាក់បៀវត្ស និងការគាំពារផ្សេងៗ
- គ្រប់គ្រងវត្តមានមន្ត្រីរាជការរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងស្ថិតិបុគ្គលិកជាប់កិច្ចសន្យា របស់អគ្គនាយកដ្ឋានសម្របសម្រួលនិងរៀបចំកម្មវិធីប្រជុំ និងរៀបចំរបាយការណ៍នៃកិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន
- ការងារពិធីការ និងទំនាក់ទំនងសាធារណៈរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋាន
- រៀបចំ និងសម្របសម្រួលកម្មវិធីបណ្តុះបណ្តាលផ្សេងៗរបស់អគ្គនាយកដ្ឋាន
- បំពេញការងារពាក់ព័ន្ធផ្សេងទៀតតាមការចាត់តាំង។

## ជំពូកទី៤
## នាយកដ្ឋានសហប្រតិបត្តិការទ្វេភាគី

**ប្រការ១១.-**

នាយកដ្ឋានសហប្រតិបត្តិការទ្វេភាគី បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើការងារសហប្រតិបត្តិការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកទេសជាមួយដៃគូអភិវឌ្ឍន៍ទ្វេភាគី និងការងារផ្សេងទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន និងក្រសួង។

**ប្រការ១២.-**

នាយកដ្ឋានសហប្រតិបត្តិការទ្វេភាគី មានការិយាល័យក្រោមឱវាទចំនួន ៣ ដូចខាងក្រោម÷

១. ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី១

២. ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី២

៣. ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី៣

**ប្រការ១៣.-**

ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី១ ទទួលបន្ទុកហិរញ្ញប្បទានសហប្រតិបត្តិការ និងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកទេស ជាមួយប្រទេសជប៉ុន និង សាធារណរដ្ឋកូរ៉េ ដោយមានភារកិច្ចលម្អិតដូចមានចែងក្នុងប្រការ១៦។

**ប្រការ១៤.-**

ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី២ ទទួលបន្ទុកហិរញ្ញប្បទានសហប្រតិបត្តិការ និងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកទេស ជាមួយប្រទេសនានាក្នុងទ្វីបអាស៊ី និងអូសេអានី លើកលែងតែប្រទេសជប៉ុន និងសាធារណរដ្ឋកូរ៉េ ដោយមានភារកិច្ចលម្អិតដូចមានចែងក្នុងប្រការ១៦។

**ប្រការ១៥.-**

ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី៣ ទទួលបន្ទុកហិរញ្ញប្បទានសហប្រតិបត្តិការ និងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកទេស ជាមួយប្រទេសបារាំង, ប្រទេសអាល្លឺម៉ង់, និងបណ្ដាប្រទេសផ្សេងទៀតពីទ្វីបអឺរ៉ុប អាមេរិក និងអាហ្វ្រិក ដោយមានភារកិច្ចលម្អិតដូចមានចែងក្នុងប្រការ១៦។

**ប្រការ១៦.-**

ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី១ ការិយាល័យសហប្រតិបត្តិការទ្វេភាគីទី២ និងការិយាល័យសហប្រតិបត្តិការទ្វេភាគីទី៣ នៃនាយកដ្ឋានសហប្រតិបត្តិការទ្វេភាគី ទទួលបន្ទុកការងារសហប្រតិបត្តិការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកទេស ជាមួយដៃគូអភិវឌ្ឍន៍ទ្វេភាគីរៀងៗខ្លួន ដោយមានភារកិច្ច ដូចតទៅ÷

- ចូលរួមក្នុងការងាររៀបចំនិងអនុវត្តគោលនយោបាយ ឬកម្មវិធីទទួលហិរញ្ញប្បទានសហប្រតិបត្តិការ
- ចូលរួម និងសម្របសម្រួល ក្នុងដំណើរការចរចាក្របខណ្ឌគោលនយោបាយនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកទេសនានា
- រៀបចំផែនការចំណូល-ចំណាយហិរញ្ញប្បទានសហប្រតិបត្តិការ រួមទាំង មូលនិធិទ្រទ្រង់ថវិកា និងចំណាយថវិកាបដិភាគ
- ចូលរួមជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ក្នុងការងារសិក្សាលទ្ធិលទ្ធភាព និងការងាររៀបចំគម្រោងដើម្បីស្នើហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- សហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ក្នុងការគ្រប់គ្រងនិងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ តាមរយៈការត្រួតពិនិត្យការទូទាត់ និងការងារលទ្ធកម្ម ចំពោះគម្រោងដែលត្រូវអនុវត្តនីតិវិធីដៃគូអភិវឌ្ឍន៍ និង/ឬ នីតិវិធីរួមសម្រាប់ការគ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- តាមដាននិងត្រួតពិនិត្យជាប្រចាំ លើការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ មូលនិធិទ្រទ្រង់ថវិកា និងថវិកាបដិភាគ
- គ្រប់គ្រងគណនីគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ មូលនិធិទ្រទ្រង់ថវិកា និងថវិកាបដិភាគ
- សម្របសម្រួលការរៀបចំនិងចរចាលើរាល់កិច្ចព្រមព្រៀងរបស់រដ្ឋ ជាមួយដៃគូអភិវឌ្ឍន៍ ពាក់ព័ន្ធនឹងការទទួលហិរញ្ញប្បទានឥតសំណង ការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី ព្រមទាំងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងៗទៀត

- ចូលរួមក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគសាធារណៈ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា
- ចូលរួមពិនិត្យឡើងវិញលើនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ព្រមទាំងនីតិវិធីពាក់ព័ន្ធផ្សេងៗទៀត
- ធ្វើបញ្ជីកាប្រតិបត្តិការហិរញ្ញវត្ថុគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ រួមទាំង មូលនិធិទ្រទ្រង់ថវិកា និងថវិកាបដិភាគ
- រៀបចំ ឬចូលរួមកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍ទ្វេភាគីនានា ដូចជា កិច្ចប្រជុំគណៈកម្មាធិការអន្តររដ្ឋាភិបាល កិច្ចប្រជុំពិគ្រោះយោបល់កម្រិតគោលនយោបាយ កិច្ចប្រជុំគណៈកម្មការចម្រុះ ជាដើម
- រៀបចំរបាយការណ៍ពាក់ព័ន្ធ
- បំពេញការងារពាក់ព័ន្ធផ្សេងទៀតតាមការចាត់តាំង។

## ជំពូកទី ៥
## នាយកដ្ឋានសហប្រតិបត្តិការពហុភាគី

**ប្រការ១៧.-**

នាយកដ្ឋានសហប្រតិបត្តិការពហុភាគី បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើការងារសហប្រតិបត្តិការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកទេសជាមួយដៃគូអភិវឌ្ឍន៍ពហុភាគី, គ្រប់គ្រង និងសម្របសម្រួលការរៀបចំ និងអនុវត្តគម្រោងហិរញ្ញប្បទានពីការឱ្យខ្ចីផ្ទាល់ និងពីមូលបត្ររដ្ឋ ព្រមទាំងការងារផ្សេងទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន និងក្រសួង។

**ប្រការ១៨.-**

នាយកដ្ឋានសហប្រតិបត្តិការពហុភាគី មានការិយាល័យក្រោមឱវាទ ចំនួន ៣ ដូចខាងក្រោម÷

១. ការិយាល័យសហប្រតិបត្តិការពហុភាគីទី១

២. ការិយាល័យសហប្រតិបត្តិការពហុភាគីទី២

៣. ការិយាល័យសហប្រតិបត្តិការពហុភាគីទី៣

**ប្រការ១៩.-**

ការិយាល័យសហប្រតិបត្តិការពហុភាគីទី១ ទទួលបន្ទុកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកទេសជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិហេដ្ឋារចនាសម្ព័ន្ធអាស៊ាន ដោយមានភារកិច្ចលម្អិតដូចមានចែងក្នុងប្រការ២២។

**ប្រការ២០.-**

ការិយាល័យសហប្រតិបត្តិការពហុភាគីទី២ ទទួលបន្ទុកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកទេសជាមួយក្រុមធនាគារពិភពលោក និងមូលនិធិសកល ដោយមានភារកិច្ចលម្អិតដូចមានចែងក្នុងប្រការ២២។

**ប្រការ២១.-**

ការិយាល័យសហប្រតិបត្តិការពហុភាគីទី៣ ទទួលបន្ទុកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកទេសជាមួយធនាគារវិនិយោគអឺរ៉ុប, ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី, មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម, សហភាពអឺរ៉ុប, និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិពហុភាគីផ្សេងទៀត ព្រមទាំងគ្រប់គ្រង និងសម្របសម្រួលការរៀបចំ និងអនុវត្តគម្រោងហិរញ្ញប្បទានពីការឱ្យខ្ចីផ្ទាល់ និងពីមូលបត្ររដ្ឋ ដោយមានភារកិច្ចលម្អិតដូចមានចែងក្នុងប្រការ២២។

**ប្រការ២២.-**

ការិយាល័យសហប្រតិបត្តិការពហុភាគីទី១ ការិយាល័យសហប្រតិបត្តិការពហុភាគីទី២ និងការិយាល័យសហប្រតិបត្តិការពហុភាគីទី៣ នៃនាយកដ្ឋានសហប្រតិបត្តិការពហុភាគី ទទួលបន្ទុកការងារសហប្រតិបត្តិការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកទេស ជាមួយដៃគូអភិវឌ្ឍន៍រៀងៗខ្លួន ដោយមានភារកិច្ច ដូចតទៅ÷

- ចូលរួមក្នុងការងាររៀបចំនិងអនុវត្តគោលនយោបាយ ឬកម្មវិធីទទួលហិរញ្ញប្បទានសហប្រតិបត្តិការ
- រៀបចំផែនការចំណូល-ចំណាយហិរញ្ញប្បទានសហប្រតិបត្តិការ រួមទាំង មូលនិធិទ្រទ្រង់ថវិកា និងចំណាយថវិកាបដិភាគ, ហិរញ្ញប្បទានពីការឱ្យខ្ចីផ្ទាល់ និងពីមូលបត្ររដ្ឋ
- ចូលរួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការងារសិក្សាសមិទ្ធិលទ្ធភាព និងការងាររៀបចំគម្រោងដើម្បីស្នើហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍, គម្រោងហិរញ្ញប្បទានពីការឱ្យខ្ចីផ្ទាល់ និងពីមូលបត្ររដ្ឋ
- សម្របសម្រួលការរៀបចំ និងចរចាលើរាល់កិច្ចព្រមព្រៀងរបស់រដ្ឋ ជាមួយដៃគូអភិវឌ្ឍន៍ ពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានឥតសំណង ការទទួលហិរញ្ញប្បទានឥតសំណង ការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី ព្រមទាំងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងៗទៀត
- គ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍន៍ពហុភាគី, មូលនិធិទ្រទ្រង់ថវិកា, និងគម្រោងហិរញ្ញប្បទានពីការឱ្យខ្ចីផ្ទាល់
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការគ្រប់គ្រងនិងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍, មូលនិធិថវិកា, និងគម្រោងហិរញ្ញប្បទានពីការឱ្យខ្ចីផ្ទាល់ និងពីមូលបត្ររដ្ឋ តាមរយៈការត្រួតពិនិត្យការទូទាត់ និងការងារលទ្ធកម្ម ចំពោះគម្រោងដែលត្រូវអនុវត្តនីតិវិធីដៃគូអភិវឌ្ឍន៍ និង/ឬ នីតិវិធីរួមសម្រាប់ការគ្រប់គ្រង ការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដើម្បីធានាអនុលោមភាពតាមគោលដៅគម្រោង/កម្មវិធី, វិធាន និងនីតិវិធីជាធរមាន
- តាមដាននិងត្រួតពិនិត្យជាប្រចាំ លើការប្រើប្រាស់មូលនិធិទ្រទ្រង់ថវិកា និងថវិកាបដិភាគ
- គ្រប់គ្រងគណនីគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ មូលនិធិទ្រទ្រង់ថវិកា និងថវិកាបដិភាគ
- ទូទាត់វិភាគទានសម្រាប់សមាជិកភាពកម្ពុជាក្នុងអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា និងទូទាត់ភាគហ៊ុននៃការវិនិយោគក្នុងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ
- ចូលរួមក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគសាធារណៈ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា
- ចូលរួមពិនិត្យឡើងវិញលើនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ព្រមទាំងនីតិវិធីពាក់ព័ន្ធផ្សេងៗទៀត
- ធ្វើបញ្ជិកាប្រតិបត្តិការហិរញ្ញវត្ថុគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ រួមទាំង មូលនិធិទ្រទ្រង់ថវិកា និងថវិកាបដិភាគ
- រៀបចំរបាយការណ៍ពាក់ព័ន្ធ
- បំពេញការងារពាក់ព័ន្ធផ្សេងទៀតតាមការចាត់តាំង។

## ជំពូកទី៦
## នាយកដ្ឋានគ្រប់គ្រងបំណុល

**ប្រការ២៣.-**

នាយកដ្ឋានគ្រប់គ្រងបំណុល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើការងារគ្រប់គ្រងបំណុលសាធារណៈ ដោយរួមទាំងមូលបត្ររដ្ឋ ដោយមានភារកិច្ច ដូចតទៅ÷

- រៀបចំ ពិនិត្យ និងតាមដានការអនុវត្តឯកសារគោលនយោបាយ យុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ដោយរួមទាំងមូលបត្ររដ្ឋ
- វិភាគចីរភាពបំណុល ចង្កោមបំណុល ធាតុអំណោយនៃឥណទាន និងហានិភ័យបំណុលពាក់ព័ន្ធ ដោយរួមទាំងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ
- គ្រប់គ្រង និងតាមដានហានិភ័យបំណុលពាក់ព័ន្ធ ដោយរួមទាំងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ
- តាមដានការអនុវត្ត និងធ្វើបច្ចុប្បន្នកម្មនីតិវិធីប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ (SOPs for PDM) និងការវាយតម្លៃប្រតិបត្តិការនៃការគ្រប់គ្រងបំណុលសាធារណៈ (DeMPA)
- គ្រប់គ្រងមូលនិធិបម្រុង (Contingency Fund) សម្រាប់ត្រៀមដោះស្រាយបំណុលសាធារណៈដែលកើតចេញពីកាតព្វកិច្ចបំណុលជាយថាហេតុ
- ធ្វើសវនកម្មផ្ទៃក្នុងលើប្រតិបត្តិការនៃការគ្រប់គ្រងបំណុលសាធារណៈ ព្រមទាំងដឹកនាំការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យបំណុល និងទិន្នន័យពាក់ព័ន្ធ
- រៀបចំ និងបោះផ្សាយព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ និងរបាយការណ៍ពាក់ព័ន្ធ
- ចូលរួមពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងកិច្ចព្រមព្រៀងស្ដីពីហិរញ្ញប្បទានឥតសំណង, ការខ្ចីប្រាក់ពីគេ, និងការឱ្យប្រាក់គេខ្ចី
- ចូលរួមក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគសាធារណៈ សេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា
- ទូទាត់សេវាបំណុលសាធារណៈក្នុង និងក្រៅប្រទេស ព្រមទាំងការប្រមូលចំណូលសេវាបំណុលពីឥណាយិកក្រោមក្របខណ្ឌនៃការឱ្យប្រាក់គេខ្ចី
- កត់ត្រាទិន្នន័យបំណុល, ទិន្នន័យកាតព្វកិច្ចបំណុលជាយថាហេតុ, និងទិន្នន័យពាក់ព័ន្ធផ្សេងទៀត ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុល (DMFAS), ប្រព័ន្ធគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities Database), និងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ (In-house Database for PDM)
- ចូលរួមអនុវត្តការងារពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)
- គ្រប់គ្រងប្រព័ន្ធ Database ទាំងអស់របស់នាយកដ្ឋាន
- គ្រប់គ្រងគម្រោងពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ
- ចូលរួមរៀបចំ និងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់អគ្គនាយកដ្ឋាន
- បំពេញការងារផ្សេងទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន និងក្រសួង។

**ប្រការ២៤.-**

នាយកដ្ឋានគ្រប់គ្រងបំណុល មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

១. ការិយាល័យវិភាគបំណុល

២. ការិយាល័យទូទាត់សេវាបំណុល

៣. ការិយាល័យរដ្ឋបាល និងព័ត៌មានវិទ្យា

៤. ការិយាល័យមូលបត្ររដ្ឋ

**ប្រការ២៥.-**

ការិយាល័យវិភាគបំណុល មានភារកិច្ច ដូចតទៅ÷

- រៀបចំ ពិនិត្យ និងតាមដានការអនុវត្តឯកសារគោលនយោបាយ យុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ដោយរួមទាំងមូលបត្ររដ្ឋ
- វិភាគចីរភាពបំណុល ចង្កោមបំណុល ធាតុអំណោយនៃឥណទាន និងហានិភ័យបំណុលពាក់ព័ន្ធ ដោយរួមទាំងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ
- គ្រប់គ្រង និងតាមដានហានិភ័យបំណុលពាក់ព័ន្ធ ដោយរួមទាំងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ
- តាមដានការអនុវត្ត និងធ្វើបច្ចុប្បន្នកម្មនីតិវិធីប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ (SOPs for PDM) និងការវាយតម្លៃប្រតិបត្តិការនៃការគ្រប់គ្រងបំណុលសាធារណៈ (DeMPA)
- គ្រប់គ្រងមូលនិធិបម្រុង (Contingency Fund) សម្រាប់ត្រៀមដោះស្រាយបំណុលសាធារណៈដែលកើតចេញពីកាតព្វកិច្ចបំណុលជាយថាហេតុ
- ចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពី ហិរញ្ញប្បទានឥតសំណង, ការខ្ចីប្រាក់ពីគេ, និងការឱ្យប្រាក់គេខ្ចី
- ចូលរួមក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគសាធារណៈ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា
- បំពេញការងារពាក់ព័ន្ធផ្សេងទៀតតាមការចាត់តាំង។

**ប្រការ២៦**.-

ការិយាល័យទូទាត់សេវាបំណុល មានភារកិច្ច ដូចតទៅ÷

- ទូទាត់សេវាបំណុលសាធារណៈក្នុង និងក្រៅប្រទេស
- គ្រប់គ្រង និងតាមដានការប្រមូលចំណូលសេវាបំណុលពីឥណាយិក ក្រោមក្របខណ្ឌនៃការឱ្យប្រាក់គេខ្ចី
- ចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពី ហិរញ្ញប្បទានឥតសំណង, ការខ្ចីប្រាក់ពីគេ, និងការឱ្យប្រាក់គេខ្ចី
- ពិនិត្យ និងផ្ទៀងផ្ទាត់ការកត់ត្រាទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុល (DMFAS) នៅដំណាក់កាលទូទាត់ និងប្រមូលសេវាបំណុល
- ពិនិត្យ ផ្ទៀងផ្ទាត់ និងរៀបចំឯកសារបញ្ជាក់សមតុល្យសន្និធិបំណុល ក្រោមក្របខ័ណ្ឌនៃការខ្ចីប្រាក់ពីគេ និងការឱ្យប្រាក់គេខ្ចី
- ចូលរួមអនុវត្តការងារពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)
- បំពេញការងារពាក់ព័ន្ធផ្សេងទៀតតាមការចាត់តាំង។

**ប្រការ២៧**.-

ការិយាល័យរដ្ឋបាល និងព័ត៌មានវិទ្យា មានភារកិច្ច ដូចតទៅ÷

- ជាច្រកចេញ-ចូលសម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន
- កត់ត្រាទិន្នន័យបំណុល, ទិន្នន័យកាតព្វកិច្ចបំណុលជាយថាហេតុ, និងទិន្នន័យពាក់ព័ន្ធផ្សេងទៀត ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុល (DMFAS), ប្រព័ន្ធគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities Database), និងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ (In-house Database for PDM)
- គ្រប់គ្រងប្រព័ន្ធ Database ទាំងអស់របស់នាយកដ្ឋាន

- ពិនិត្យ និងផ្ទៀងផ្ទាត់ការកត់ត្រាទិន្នន័យ ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុល (DMFAS) នៅដំណាក់កាលកត់ត្រា និងរៀបចំរបាយការណ៍
- រៀបចំ បោះផ្សាយ និងចែកចាយព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈ
- រៀបចំរបាយការណ៍បំណុល និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀតរបស់នាយកដ្ឋាន
- ចូលរួមក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគសាធារណៈ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា
- ចូលរួមអនុវត្តការងារពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)
- សិក្សា និងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា (Supporting Tools) ដើម្បីសម្រួលដល់ប្រតិបត្តិការការងារប្រចាំថ្ងៃ
- គ្រប់គ្រងឥណទានថវិកាសេវាបំណុលសាធារណៈ
- គ្រប់គ្រងគម្រោងពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ
- ចូលរួមរៀបចំ និងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងវត្តមានមន្ត្រី និងឯកសាររបស់នាយកដ្ឋាន
- បំពេញការងារពាក់ព័ន្ធផ្សេងទៀតតាមការចាត់តាំង។

**ប្រការ២៨.-**

ការិយាល័យមូលបត្ររដ្ឋ មានភារកិច្ច ដូចតទៅ÷

- ចូលរួមរៀបចំ សម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអភិវឌ្ឍមូលបត្ររដ្ឋ
- សម្របសម្រួលលើរាល់កិច្ចការបច្ចេកទេសពាក់ព័ន្ធនឹងមូលបត្ររដ្ឋ ជាមួយអាណត្តិគាហក និងតួអង្គពាក់ព័ន្ធផ្សេងទៀត
- រៀបចំ និងផ្សព្វផ្សាយផែនការបោះផ្សាយមូលបត្ររដ្ឋ (Issuance Plan)
- ពិគ្រោះយោបល់ជាមួយអ្នកចូលរួមក្នុងទីផ្សារ (Market Sounding)
- អភិវឌ្ឍឧបករណ៍មូលបត្ររដ្ឋ (Government Securities Instruments)
- សិក្សា និងបង្កើតខ្សែកោងទិន្នផល (Yield Curve)
- ចូលរួមកិច្ចការអភិវឌ្ឍទីផ្សារមូលបត្រ (Securities Market)
- ចូលរួមក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគសាធារណៈ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា
- បំពេញការងារពាក់ព័ន្ធផ្សេងទៀតតាមការចាត់តាំង។

## ជំពូកទី៧

## នាយកដ្ឋានតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង

**ប្រការ២៩.-**

នាយកដ្ឋានតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើការងារតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ទាំងក្របខណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី, ពីការឱ្យខ្ចីផ្ទាល់, និងពីមូលបត្ររដ្ឋ និងការងារផ្សេងទៀតតាមការចាត់តាំងរបស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន និងក្រសួង។

**ប្រការ៣០.-**

នាយកដ្ឋានតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង មានការិយាល័យក្រោមឱវាទចំនួន ៣ ដូចខាងក្រោម÷

១. ការិយាល័យតាមដាន និងត្រួតពិនិត្យគម្រោងទី១

២. ការិយាល័យតាមដាន និងត្រួតពិនិត្យគម្រោងទី២

៣. ការិយាល័យគ្រប់គ្រងទិន្នន័យគម្រោង

**ប្រការ៣១.-**

ការិយាល័យតាមដាន និងត្រួតពិនិត្យគម្រោងទី១ ទទួលបន្ទុកការងារតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង/កម្មវិធីហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុនិងដៃគូអភិវឌ្ឍន៍ទ្វេភាគី និងមូលនិធិទ្រទ្រង់ថវិកា ដោយមានភារកិច្ចលម្អិតដូចមានចែងក្នុងប្រការ៣៣។

**ប្រការ៣២.-**

ការិយាល័យតាមដាន និងត្រួតពិនិត្យគម្រោងទី២ ទទួលបន្ទុកការងារតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង/កម្មវិធីហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុនិងដៃគូអភិវឌ្ឍន៍ពហុភាគី និងមូលនិធិទ្រទ្រង់ថវិកា ដោយមានភារកិច្ចលម្អិតដូចមានចែងក្នុងប្រការ៣៣ ព្រមទាំងតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោងហិរញ្ញប្បទានពីការឱ្យខ្ចីផ្ទាល់, និងពីមូលបត្ររដ្ឋ។

**ប្រការ៣៣.-**

ការិយាល័យតាមដាន និងត្រួតពិនិត្យគម្រោងទី១ និងការិយាល័យតាមដាន និងត្រួតពិនិត្យគម្រោងទី២ នៃនាយកដ្ឋានតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង ទទួលបន្ទុកការងារតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង/កម្មវិធីជាមួយស្ថាប័នហិរញ្ញវត្ថុនិងដៃគូអភិវឌ្ឍន៍រៀងៗខ្លួន ដោយមានភារកិច្ចលម្អិតដូចតទៅ÷

- ចូលរួមផ្តល់យោបល់លើការងាររៀបចំគម្រោង និងធ្វើការវាយតម្លៃលើភាពរួចរាល់នៃគម្រោង
- ចូលរួមចរចាលើរាល់កិច្ចព្រមព្រៀងរបស់រដ្ឋ ជាមួយដៃគូអភិវឌ្ឍន៍ ពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានឥតសំណង ការទទួលហិរញ្ញប្បទានឥតសំណង ការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី ព្រមទាំងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងៗទៀត
- តាមដាន និងវាយតម្លៃលើសមិទ្ធកម្មនៃការអនុវត្តគម្រោង និងផ្តល់អនុសាសន៍ដំណោះស្រាយបញ្ហា និងវិធានការកែតម្រូវជាប្រព័ន្ធ ហើយរាយការណ៍ជូនថ្នាក់ដឹកនាំតាមការចាំបាច់
- សម្របសម្រួលការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ព្រមទាំងរៀបចំនីតិវិធីពាក់ព័ន្ធបន្ថែម តាមការចាំបាច់
- ចូលរួមជាសមាជិកក្នុងគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម (Procurement Review Committee) កម្រិតធំ និងកម្រិតមធ្យម
- ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តគម្រោង (Portfolio Review) ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមការចាំបាច់ ព្រមទាំងរៀបចំរបាយការណ៍តាមដានប្រសិទ្ធភាពនៃការអនុវត្តគម្រោង
- តាមដាន និងត្រួតពិនិត្យការអនុវត្តវិធានការ និងផែនការសម្មភាពដែលបានឯកភាពរួមគ្នា (Joint Action Plan) រវាងរាជរដ្ឋាភិបាល ជាមួយដៃគូអភិវឌ្ឍន៍ ស្តីពីការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តគម្រោង
- សម្របសម្រួលដំណើរការចុះធ្វើសវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំលើការអនុវត្តគម្រោង ព្រមទាំងតាមដាន និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តតាមអនុសាសន៍របស់សវនករឯករាជ្យ
- រៀបចំ, បង្កើត, និងគ្រប់គ្រងប្រព័ន្ធតាមដាននិងវាយតម្លៃសមិទ្ធកម្មគម្រោង
- ចូលរួមផ្តល់យោបល់លើរបាយការណ៍ស្តីពីការបញ្ចប់គម្រោង (Project Completion Report)

- សម្របសម្រួលការងារវាយតម្លៃក្រោយបញ្ចប់គម្រោង (Project Impact/Performance Evaluation) តាមការចាំបាច់
- ចូលរួមក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគសាធារណៈ សេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា
- រៀបចំសកម្មភាពបណ្ដុះបណ្ដាលចាំបាច់នានាសម្រាប់ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគម្រោង
- បំពេញការងារពាក់ព័ន្ធផ្សេងទៀតតាមការចាត់តាំង។

**ប្រការ៣៤.-**

ការិយាល័យគ្រប់គ្រងទិន្នន័យគម្រោង មានភារកិច្ច ដូចតទៅ÷

- រៀបចំ, កសាង, និងគ្រប់គ្រងប្រតិបត្តិការប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ (PPDMS) ព្រមទាំងធ្វើបច្ចុប្បន្នភាពប្រព័ន្ធនេះ តាមការចាំបាច់
- សម្របសម្រួលលើការកត់ត្រាទិន្នន័យគម្រោង និងទិន្នន័យពាក់ព័ន្ធផ្សេងទៀត ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- ពិនិត្យ និងផ្ទៀងផ្ទាត់ទិន្នន័យគម្រោង និងទិន្នន័យពាក់ព័ន្ធ
- រៀបចំសៀវភៅណែនាំស្ដីពីរបៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ព្រមទាំងធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំនេះ តាមការចាំបាច់
- រៀបចំការបណ្ដុះបណ្ដាលពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដល់អ្នកប្រើប្រាស់ និងអ្នកពាក់ព័ន្ធផ្សេងទៀត
- សម្របសម្រួលការចូលរួមអនុវត្តការងារពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ (PIPDMS)
- សិក្សា និងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់សម្រួលដល់ប្រតិបត្តិការការងារគ្រប់គ្រងគម្រោង និងការងារប្រចាំថ្ងៃរបស់នាយកដ្ឋាន
- សហការ និងសម្របសម្រួលជាមួយស្ថាប័នជាតិ និងដៃគូអភិវឌ្ឍន៍ ក្នុងការរៀបចំកម្មវិធីបណ្ដុះបណ្ដាលពាក់ព័ន្ធផ្សេងៗ
- បំពេញការងារពាក់ព័ន្ធផ្សេងទៀតតាមការចាត់តាំង។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ៣៥.-**

ក្នុងពេលបំពេញការងារ ភារកិច្ចទាំងឡាយណា ដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានជំនាញដទៃ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ត្រូវសហការជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធទាំងនោះ ដើម្បីរួមគ្នាដោះស្រាយ ឬស្នើសុំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការកំណត់ ឬបែងចែកភារកិច្ចទាំងនោះ។

**ប្រការ៣៦.-**

ប្រកាសនេះ ត្រូវជំនួសប្រកាស ដូចខាងក្រោម÷

- ប្រកាសលេខ ៦៦៦ សហវ.ប្រក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល

- ប្រកាសលេខ ១១៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមការិយាល័យមួយចំនួនក្រោមឱវាទនាយកដ្ឋានសហប្រតិបត្តិការពហុភាគី នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែមេសា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៣៧
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ........ សហវ.ប្រក ចុះថ្ងៃទី...... ខែ...... ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ
នៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**អង្គការលេខរបស់អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
